រាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៩៩

## ២-សេចក្ដីសំរេច

### សេចក្ដីសំរេចលេខ ៧៤ សសរ

### ស្ដីពីការបង្កើតគណៈកម្មការ ចំរុះមួយសំរាប់ដោះស្រាយជុំវិញបញ្ហាពាក់ព័ន្ធ និងសំណង់ របស់ប្រជាជនក្រីក្រ នៅជាប់របងស្ថានទូតថៃ និង ជប៉ុន

****

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពី ការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់ របស់រាជរដ្ឋាភិបាល

### សំរេច

ប្រការ ១ : បង្កើតគណៈកម្មការចំរុះមួយសំរាប់ដោះស្រាយ ជុំវិញបញ្ហាពាក់ព័ន្ធ និង សំណង់របស់ប្រជាជនក្រីក្រ នៅជាប់របងស្ថានទូត ថៃ និង ជប៉ុន ។

ប្រការ ២ : គណៈកម្មការនេះមានសមាសភាពដូចតទៅ :

១-ឯកឧត្ដម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ជាប្រធាន

២-ឯកឧត្ដម អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ជាសមាជិក

៣-ឯកឧត្ដម អ៊ុច គឹមអាន រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

៤-ឯកឧត្ដម អ៊ុក រ៉ាប៊ុន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសមាជិក

៥-ឯកឧត្ដម ជា សុផារ៉ា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ជាសមាជិក

៦-ឯកឧត្ដម ម៉ុល លឹម តំណាងក្រសួងមហាផ្ទៃ ជាសមាជិក

ប្រការ ៣ : គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម :

-ចុះពិនិត្យបញ្ហាជាក់ស្ដែងនៅ និង កន្លែង មានវិវាទ

-ប្រមូលអោយបានគ្រប់ទិន្នន័យ ដែលពាក់ព័ន្ធដើម្បីរកដំណោះស្រាយសមស្រប

-ផ្អែកលើទិន្នន័យជាក់ស្ដែង ទាំងនេះ វាយតំលៃ និង កំណត់រូបមន្តដំណោះស្រាយមួយដែលអាច ទទួលបាន រវាងភាគីពាក់ព័ន្ធ ដើម្បីបញ្ចប់បញ្ហាជាស្ថាពរ ។

ប្រការ ៤ : គណៈកម្មការនេះត្រូវរំសាយ ជាស្វ័យប្រវត្តិ នៅពេលដែលដំណោះស្រាយបញ្ហាខាងលើត្រូវបាន បញ្ចប់ជាស្ថាពរ ។

ប្រការ ៥ ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃរដ្ឋាករទីក្រុងភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ព្រមទាំងឯកឧត្តម សាមី ដែលមានចែងក្នុងប្រការ ២ មានភារកិច្ចអនុវត្តអោយមានប្រសិទ្ធភាព នូវសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## IV- ធនាគារកណ្តាលក្នុងស្រុក

### ១- ធនាគារជាតិនៃកម្ពុជា

### ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩

**ប្រកាសលេខ ធ៨-៩៩ ១២២ ប្រក**

**ស្តីពីលក្ខន្តិកៈដោយឡែក**

**នៃក្របខ័ណ្ឌលេខាធិការធនាគារជាតិនៃកម្ពុជា**

***

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៩៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- យោងតាមការអនុមតិរបស់អង្គប្រជុំក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩៩

**សំរេច**

**ជំពូកទី ១**

**បទបញ្ញត្តិទូទៅ**

ប្រការ ១ ៈ បង្កើតលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌលេខាធិការធនាគារជាតិកម្ពុជា ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ គ ។